# ជនសន្ធជាតក



ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ទ្រង់ត្រាស់ព្រះធម្មទេសនានេះ ដើម្បីឲ្យឱវាទដល់ព្រះបាទកោសល មានពាក្យថា **ទស ខលុ** ដូច្នេះជាដើម ។

ពេលមួយ ព្រះរាជាស្រវឹងដោយឥស្សរិយយស ដែលអាស្រ័យនឹងសេចក្តីសុខក្នុងកិលេស ទ្រង់មិនតាំងទុកការវិនិច្ឆ័យក្តី ធ្វេសប្រហែសសូម្បីក្នុងការបម្រើព្រះពុទ្ធ ។ ថ្ងៃមួយ ព្រះរាជានោះរឭកព្រះទសពល ទ្រង់គិតថា យើងនឹងថ្វាយបង្គំព្រះសាស្តា ដូច្នេះកាលស្តេចសោយក្រយាពេលព្រឹករួច ក៏ទ្រង់ឡើងលើរថដ៏ប្រសើរ យាងទៅវត្ត ថ្វាយបង្គំព្រះសាស្តា ហើយស្តេចគង់ (ក្នុងទីដ៏សមគួ) ។

ពេលនោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា បពិត្រមហារាជ ហេតុដូចម្តេច បានជាទ្រង់មិនប្រាកដ អស់កាលដ៏យូរ ?

ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានកិច្ចការងារច្រើន ទើបមិនមានឱកាសនឹងមកបម្រើព្រះពុទ្ធ ។

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ កាលព្រះសព្វញ្ញុពុទ្ធ ជាអ្នកឲ្យឱវាទ ដូចជាតថាគត នៅនឹងវត្តដែលជិត ព្រះអង្គមិនគួរប្រមាទឡើយ ធម្មតាព្រះរាជាគប្បីមិនប្រមាទក្នុងរាជកិច្ច ត្រូវប្រព្រឹត្តស្មើក្នុងមាតាបិតា និងពួកអ្នកដែន ត្រូវលះបង់ដំណើរអគតិ មិនត្រូវញ៉ាំងទសរាជធម៌ឲ្យកម្រើក គួរសោយរាជសម្បត្តិដោយធម៌ បើព្រះរាជាដែលប្រកបដោយធម៌ សូម្បីបរិស័ទក៏ជាអ្នកប្រកបដោយធម៌ដែរ ការដែលតថាគតជាអ្នកឲ្យឱវាទ ហើយព្រះអង្គសោយរាជសម្បត្តិប្រកបដោយធម៌នេះ មិនជាអស្ចារ្យទេ បោរាណបណ្ឌិតទាំងឡាយ សូម្បីមិនមានអាចារ្យប្រៀនប្រដៅ (ក៏អាច) សម្តែងធម៌ ដល់មហាជន ឲ្យតាំងនៅក្នុងសុចរិតធម៌ទាំង ៣ ដោយមតិរបស់ខ្លួន ហើយទៅកាន់ផ្លូវសួគ៌ ។ កាលព្រះរាជាទូលអង្វរអារាធនា ទ្រង់នាំយកអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទៃអគ្គមហេសីរបស់ព្រះរាជានោះ (ពេលប្រសូតហើយ) ពពួកញាតិថ្វាយព្រះនាមថា **ជនសន្ធកុមារ** ។ ព្រះរាជាបញ្ជា**ជនសន្ធកុមារ** ដែលធំហើយ ដែលបានទៅរៀនសិល្បសាស្ត្រ រួចត្រឡប់មកពីនគរតក្កសិលា ឲ្យជម្រះពន្ធនាគារទាំងអស់ ហើយទ្រង់ប្រទានតំណែងជាឧបរាជ ។ កាលកន្លងទៅនៃបិតា ព្រះពោធិសត្វក៏បានតាំងក្នុងរាជសម្បត្តិ ទ្រង់ឲ្យគេកសាងសាលាទាន ៦ កន្លែង គឺត្រង់ទ្វារនគរ ៤ កន្លែង ត្រង់កណ្តាលនគរ ១ កន្លែង និងត្រង់រាជទ្វារ ១ កន្លែង ទ្រង់តែងបរិច្ចាគទ្រព្យ ៦ សែន រាល់ៗថ្ងៃ ញ៉ាំងសកលជម្ពូទ្វីបឲ្យកម្រើក ធ្វើឲ្យមហាទានព្រឹត្តទៅ ទ្រង់បញ្ជាឲ្យបើកពន្ធនាគារជានិច្ច ស្តេចឲ្យគេជម្រះធម្ម-

*កណ្ឌិកៈ សង្គ្រោះសត្វលោកដោយសង្គហវត្ថុទាំង ៤ ទ្រង់រក្សាសីល ៥ និងឧបោសថ សោយរាជសម្បត្តិប្រកបដោយធម៌ ។*

*ព្រះមហាសត្វ ឲ្យពួកអ្នកដែនមកប្រជុំគ្នា ហើយសម្ដែងធម៌ថា អ្នកទាំងឡាយចូរឲ្យទាន ចូរសមាទានសីល ចូរចម្រើនភាវនា ចូរប្រកបដោយការងារ និងវោហារដែលជាធម៌ ត្រូវសិក្សាសិល្បសាស្ត្រក្នុងវ័យក្មេង ហើយញ៉ាំងទ្រព្យឲ្យកើតឡើង ចូរកុំធ្វើកូដកម្មក្នុងស្រុក និងកុំធ្វើការញុះញង់ ចូរកុំពោលពាក្យអាក្រក់គ្រោតគ្រាត ចូរបម្រើមាតាបិតា ចូរចម្រើនការគោរពរៀមច្បងក្នុងត្រកូល ដូច្នេះហើយ ទ្រង់ក៏បានញ៉ាំងមហាជន ឲ្យតាំងនៅក្នុងសុចរិតធម៌ ។*

*ថ្ងៃមួយ ក្នុងថ្ងៃឧបោសថទី ១៥ ព្រះពោធិសត្វសមាទានឧបោសថហើយ គិតថា យើងនឹងសម្ដែងធម៌ ដើម្បីសេចក្ដីសុខនិងសេចក្ដីចម្រើន និងដើម្បីការនៅដោយសេចក្ដីមិនប្រមាទ ដល់មហាជនឲ្យក្រៃលែងឡើង គិតយ៉ាងនេះហើយ ទ្រង់ឲ្យរាជបុរសត្រាច់វាយស្គរក្នុងនគរ ប្រកាសឲ្យអ្នកនគរទាំងអស់ ធ្វើចាប់ពីអ្នកនៅក្នុងរាជវាំងរបស់ព្រះអង្គជាដើម មកប្រជុំគ្នា ហើយស្ដេចប្រថាប់លើបល្ល័ង្កដ៏ប្រសើរ ដែលតាក់តែងល្អហើយ ក្នុងកណ្ដាលអលង្កតរតនមណ្ឌប រួចទ្រង់ត្រាស់ថា នែអ្នកដ៏ចម្រើន យើងនឹងសម្ដែងធម៌ដែលឲ្យកើតសេចក្ដីក្ដៅក្រហាយខ្លះ មិនក្ដៅក្រហាយខ្លះ ដល់អ្នកនគរ ពួកអ្នកចូរកុំប្រមាទ ចូរមានត្រចៀកផ្ទៀងស្ដាប់ដោយគោរពចុះ ដូច្នេះហើយ ទ្រង់ក៏បានសម្ដែងធម៌ ។*

*ព្រះសាស្ដាបើករតនៈ គឺព្រះឱស្ឋ ដែលអប់រំចម្រើនដោយសច្ចៈ កាលនឹងធ្វើធម្មទេសនានោះ ឲ្យជាក់ច្បាស់ដល់ព្រះបាទកោសល ដោយសំឡេងដ៏ពីរោះ ទើបត្រាស់ព្រះគាថាទាំងឡាយនេះថា*

**ទស ខលុ ឥមានិ ឋានានិ, យានិ បុព្ពេ អការិត្វា;**
**ស បច្ឆា មនុតប្បតិ, ឥច្ចេវាហ ជនសន្ធោ។**

*ព្រះបាទជនសន្ធៈ ទ្រង់មានព្រះឱង្ការថា បុគ្គលណា មិនបានធ្វើហេតុទាំង ១០ នេះ ទុកជាមុនទេ បុគ្គលនោះ តែងក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ។*

អលទ្ធា វិត្តំ តប្បតិ, បុព្ពេ អសមុទានិតំ;
ន បុព្ពេ ធនមេសិស្សំ, ឥតិ បច្ឆានុតប្បតិ។

*បុគ្គលមិនបានទ្រព្យ ដែលខ្លួនមិនបានឲ្យកើតឡើង ក្នុងកាលមុន រមែងក្តៅក្រហាយ តែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អាត្មាអញមិនបានស្វែងរកទ្រព្យ ក្នុងកាលមុន ។*

សក្យរូបំ បុរេ សន្តំ, មយា សិប្បំ ន សិក្ខិតំ;
កិច្ឆា វុត្តិ អសិប្បស្ស, ឥតិ បច្ឆានុតប្បតិ។

*បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា សិល្បៈ ជាគុណ មានសភាពអង់អាច អាត្មាអញមិនបានរៀនទុក ក្នុងកាលមុន ការចិញ្ចឹមជីវិតនៃបុគ្គល អ្នកមិនមានសិល្បៈ លំបាក ។*

កូដវេទី បុរេ អាសិំ, បិសុណោ បិដ្ឋិមំសិកោ;
ចណ្ឌោ ច ផរុសោ ចាបិ, ឥតិ បច្ឆានុតប្បតិ។

*បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា កាលពីដើម អាត្មាអញជាអ្នកប៉ិនប្រសប់ ក្នុងអំពើរកោងផង ជាអ្នកញុះញង់ផង ស៊ីសាច់ខ្នងគេ គឺស៊ីសំណូកផង ជាអ្នកកាចផង អាក្រក់ផង ។*

បាណាតិបាតី បុរេ អាសិំ, លុទ្ទោ ចាបិ អនារិយោ;
ភូតានំ នាបចាយិស្សំ, ឥតិ បច្ឆានុតប្បតិ។

បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលខាងក្រោយថា កាលពីដើម អាត្មាអញជាអ្នកសម្លាប់សត្វផង កាចអាក្រក់ផង ជាអ្នកមិនប្រសើរផង មិនកោតក្រែងចំពោះពួកសត្វផង ។

ពហូសុ វត សន្តីសុ, អនាថាសុ ឥត្ថីសុ;
បរទារំ អសេវិស្សំ, ឥតិ បច្ឆានុតប្បតិ។

បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អើហ្ន៎ កាលដែលពួកស្ត្រីមានច្រើនគរគោក ជាស្ត្រីមិនមានអន្តរាយ (មិនមានគេកាន់កាប់សោះ) អាត្មាអញសេពនឹងប្រពន្ធគេ ។

ពហុម្ហិ វត សន្តម្ហិ, អន្នបានេ ឧបដ្ឋិតេ;
ន បុព្វេ អទទំ ទានំ, ឥតិ បច្ឆានុតប្បតិ។

បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អើហ្ន៎ កាលពីដើម អាត្មាអញមានបាយ និងទឹកច្រើនគរគោក តែមិនបានឲ្យទានសោះ ។

មាតរំ បិតរំ ចាបិ, ជិណ្ណកំ គតយោព្វនំ;
បហុ សន្តោ ន បោសិស្សំ, ឥតិ បច្ឆានុតប្បតិ។

បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា កាលអាត្មាអញ មានទ្រព្យច្រើន មិនបានចិញ្ចឹមមាតា និងបិតាដែលចាស់ មានវ័យកន្លងហើយ ។

អាចរិយមនុសត្ថារំ, សព្វកាមរសាហារំ;
បិតរំ អតិមញ្ញិស្សំ, ឥតិ បច្ឆានុតប្បតិ។

បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អាត្មាអញបានមើលងាយបិតា ដែលជាអាចារ្យ អ្នកប្រៀនប្រដៅ ជាអ្នកនាំមកនូវរសគ្រប់យ៉ាង ។

សមណេ ព្រាហ្មណេ ចាបិ, សីលវន្តេ ពហុស្សុតេ;
ន បុព្ពេ បយិរុបាសិស្សំ, ឥតិ បច្ឆានុតប្បតិ។

*បុគ្គលតែងក្ដៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា ក្នុងកាលមុន អាត្មាអញ មិនបានចូលទៅជិតពួកសមណៈ និងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូតឡើយ ។*

សាធុ ហោតិ តបោ ចិណ្ណោ, សន្តោ ច បយិរុបាសិតោ;
ន ច បុព្ពេ តបោ ចិណ្ណោ, ឥតិ បច្ឆានុតប្បតិ។

*បុគ្គលតែងក្ដៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា តបៈ គឺសុចរិតធម៌ ដែលគេសន្សំហើយផង បុគ្គលអ្នកស្ងប់ ដែលគេចូលទៅអង្គុយជិតផង ជាការប្រពៃ តបៈ (មានសភាពយ៉ាងនេះ) អាត្មាអញ មិនបានសន្សំហើយ ក្នុងកាលពីដើម ។*

យោ ច ឯតានិ ឋានានិ, យោនិសោ បដិបជ្ជតិ;
ករំ បុរិសកិច្ចានិ, ស បច្ឆា នានុតប្បតិ។

*ចំណែកខាងបុគ្គលណា កាលធ្វើកិច្ចរបស់បុរសទាំងឡាយ ហើយប្រតិបត្តិនូវហេតុ ទាំងនេះ ដោយយោបល់ បុគ្គលនោះ រមែងមិនក្ដៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយឡើយ ។*

*ព្រះមហាសត្វសម្ដែងធម៌ដល់មហាជនដោយនិយាមនេះ រាល់ៗកន្លះខែ យ៉ាងនេះឯង ។ ចំណែកមហាជនតាំងនៅក្នុងឱវាទព្រះមហាសត្វ ធ្វើឋានទាំង ១០ នោះឲ្យពេញហើយ ជាអ្នកមានសួគ៌ជាទីទៅខាងមុខ ។*

*ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា បពិត្រមហារាជ បោរាណបណ្ឌិតទាំងឡាយ សូម្បីមិនមានអាចារ្យ (ក៏អាច) សម្ដែងធម៌ដោយបញ្ញារបស់ខ្លួន ញុំាងមហាជនឲ្យតាំងនៅក្នុងផ្លូវសួគ៌យ៉ាងនេះឯង ដូច្នេះហើយទ្រង់ប្រជុំជាតកថា*

**តទា បរិសា ពុទ្ធបរិសា អហោសុំ** *បរិស័ទក្នុងកាលនោះ បានមកជា ពុទ្ធបរិស័ទ*

**ជនសន្ធរាជា បន អហមេវ អហោសឹ** *ចំណែកព្រះបាទជនសន្ធៈ គឺ តថាគត នេះឯង ។*

*ជនសន្ធជាតក បចប់ ៕*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសកនិបាត បិដកលេខ ៥៩ ទំព័រ ២៤៨)*

*ថ្ងៃ សៅរ៍ ១៣ រោច ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ៨ ខែ កញ្ញា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*